# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃនេះទី ២៦ ខែមករា ឆ្នាំ ២០២១ វេលាម៉ោង ៨ និង ៣០ នាទីព្រឹកនៅសាលប្រជុំសណ្ឋាគារសូហ្វីតែលភ្នំពេញ ភូគីតត្រា **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជា**ប្រធានគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអញ្ជើញជាអធិបតីភាពក្នុងពិធីប្រកាសផ្សព្វផ្សាយជាផ្លូវការនូវរបាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ដែលជាជំរឿនលើកទីបីក្រោយប្រទេសឆ្លងកាត់ក្នុងសង្គ្រាមកន្លងមក ។

យោងតាមលទ្ធផលជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ចំនួនប្រជាជនសរុបមាន ១៥.៥៥២.២១១ នាក់ ក្នុងនោះប្រុសចំនួន ៧.៥៧១.៨៣៧ នាក់ (៤៨.៧%) និងស្រីចំនួន៧.៩៨០.៣៧៤ នាក់ (៥១.៣%) ។ អត្រាកំនើនប្រជាជនមធ្យមប្រចាំឆ្នាំគឺ ១.៤% ។ ដូចគ្នានេះដែរ លទ្ធផលជំរឿនលើកមុន (២០០៨) ចំនួនប្រជាជនសរុបមានចំនួន ១៣.៤ លាននាក់ ពេលគឺចាប់ពីឆ្នាំ ២០០៨ ដល់ ឆ្នាំ ២០១៩ ចំនួនប្រជាជនបានកើនឡើងចំនួន ២,២ លាននាក់ ។

ភាគរយនៃប្រជាជនរស់នៅទីតំបន់ទីប្រជុំជនមានចំនួន ៣៩,៤ ភាគរយ និងនៅជនបទមាន ៦០,៦ ភាគរយ។ ខេត្តចំនួន ៤ ដែលមានប្រជាជនច្រើនជាង ១ លាននាក់ គឺរាជធានីភ្នំពេញ (២,៣ លាននាក់) ខេត្តកណ្តាល (១,២ លាននាក់) ខេត្តព្រៃវែង (១,១ លាននាក់) និងខេត្តសៀមរាប (១,០ លាននាក់)។ ចំនួនគ្រួសារនៅទូទាំងប្រទេសមាន ៣.៥៥៣.០២១ គ្រួសារ។

មានការផ្លាស់ប្តូរសំខាន់ៗនៅក្នុងរចនាសម្ព័ន្ធអាយុរបស់ប្រជាជន។ រវាងជំរឿនទាំងពីរលើក ប្រជាជនវ័យក្មេង (០-១៤ ឆ្នាំ) បានធ្លាក់ចុះពី ៣៣,០% ទៅ ២៩,៤%, ប្រជាជនវ័យកណ្តាល (១៥-៥៩ ឆ្នាំ) បានកើនឡើងពី ៦០,០% ទៅ ៦១,៧ និងមនុស្សចាស់ (៦០ ឆ្នាំនិងបូក) បានកើនឡើងពី ៦,៣% ទៅ ៨,៩% ។ មេដ្យានអាយុរបស់ប្រជាជនបានកើនឡើងពីអាយុ ២២ ទៅ ២៧ ឆ្នាំ។ តួលេខទាំងនេះបង្ហាញថាប្រជាជនកម្ពុជាកំពុងចាប់ផ្តើមវិវត្តទៅតាមអាយុគឺមានន័យថាកម្ពុជា ជាប្រទេសមានប្រជាជនវ័យចាស់ច្រើននៅពេលអនាគត ។

កត្តាកំណត់សំខាន់នៃវ័យចាស់របស់ប្រជាជនគឺ ការធ្លាក់ចុះនៃអត្រាលទ្ធភាពបង្កើតកូន និងការធ្លាក់ចុះនៃអត្រាមរណភាព។ យោងតាមលទ្ធផលជំរឿនប្រជាជនឆ្នាំ ២០០៨ អត្រាមានកូនមានកម្រិតទាបរួចទៅហើយៈ អត្រាលទ្ធភាពបង្កើតកូនសរុបគឺ ២,៧ នាក់ក្នុងស្ត្រីម្នាក់។ រីឯលទ្ធផលជំរឿនប្រជាជនឆ្នាំ២០១៩ បង្ហាញអត្រាលទ្ធភាពបង្កើតកូនសរុប (TFR) ២,៥ នាក់ក្នុងស្ត្រីម្នាក់។ អត្រាមរណភាពត្រូវបានគេសង្កេតឃើញថាមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ ។ យោងតាមការធ្វើជំរឿនឆ្នាំ ២០០៨ អត្រាមរណភាពទារកគឺការស្លាប់របស់ទារកចំនួន ២៦ នាក់ (អាយុក្រោម ១ ឆ្នាំ) ក្នុងចំណោម ១,០០០ កំណើតរស់ រីឯការធ្វើជំរឿនឆ្នាំ ២០១៩ អត្រាស្លាប់របស់ទារកមានចំនួន ១៨ នាក់ ក្នុងចំណោម

១,០០០ កំណើតរស់ ។ ហើយក៏បានបង្ហាញផងដែរអំពីមរណភាពមាតាថយចុះ ។ រវាងជំរឿនទាំងពីរលើក អត្រាមរណភាពមាតាបានធ្លាក់ចុះពី ៤៦១ នាក់ (ឆ្នាំ ២០០៨) មក ១៤១ នាក់ក្នុង(២០១៩)ចំណោម ១០០.០០០ កំណើត។

បញ្ហាចម្បងនៃការធ្វើជំរឿនគឺចំនួនប្រជាជនដែលមិនត្រូវបានរាប់ ឬមិនចូលរួមក្នុងព្រឹត្តិការណ៍នេះ។ ដោយហេតុនេះទើបប្រទេសភាគច្រើនធ្វើអង្កេតក្រោយជំរឿនដើម្បីវាយតម្លៃកម្រិតលំអៀង។ ប្រទេសកម្ពុជាបានធ្វើធ្វើអង្កេតក្រោយជំរឿននេះរួចហើយហើយលទ្ធផលបង្ហាញថា ២,៥ ភាគរយនៃប្រជាជនមិនត្រូវបានរាប់ ។ នេះគឺជាភាគរយទាប និងមិនប៉ះពាល់ដល់លទ្ធផលជំរឿនឡើយ។

ជំរឿនប្រជាជនឆ្នាំ២០១៩ មានសារសំខាន់ណាស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជាទាំងមូល ហើយក៏មានសារៈប្រយោជន៍សម្រាប់អ្នកធ្វើគោលនយោបាយ ក៏ដូចជាអ្នកដឹកនាំ និងអ្នករៀបចំផែនការផងដែរ។

ជំរឿនប្រជាជនឆ្នាំ ២០១៩ ត្រូវបានធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ក្រោមគ្រប់គ្រងរបស់គណៈកម្មាធិការជាតិជំរឿន និងការណែនាំរបស់គណៈកម្មការបច្ចេកទេសជំរឿន និងគាំទ្រស្ទើតែទាំងស្រុងពីរាជរដ្ឋាភិបាលកម្ពុជា។ ជំនួយផ្នែកហិរញ្ញវត្ថុខ្លះ និងបច្ចេកទេសមួយចំនួនបានមកពី UNFPA សាធារណរដ្ឋប្រជាមានិតចិន ជាពិសេសគឺការផ្គត់ផ្គង់ឧបករណ៍ សម្ភារៈសម្រាប់ការធ្វើជំរឿនដោយ GIZ, EU និង SIDA បានចូលរួមចំណែកផ្តល់ជំនួយសម្រាប់បណ្តាញ Network និងប្រតិបត្តិការជំរឿន។

ឆ្លៀតឱកាសនេះផងដែរវិទ្យាស្ថានជាតិស្ថិតិ ក៏សូមប្រកាសព័ត៌មានសំខាន់មួយទៀតពាក់ព័ន្ធការងារស្ថិតិកសិកម្ម។ ប្រទេសកម្ពុជាកំពុងផ្តួចផ្តើមគំនិតចូលរួមក្នុងគម្រោង ៥០x២០៣០ ដែលជាកិច្ចខិតខំប្រឹងប្រែងរបស់ដៃគូពហុភាគីបានបង្កើតឡើងក្នុងឆ្នាំ ២០១៨ ដើម្បីលើកកម្ពស់វិស័យទិន្នន័យកសិកម្មឲ្យបានល្អ ។ ថ្មីៗនេះមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD) បានចាប់ផ្តើមធ្វើការងារលើការជំរុញការប្រើប្រាស់ទិន្នន័យកសិកម្ម និងជនបទនៅកម្ពុជា។ នៅក្នុងការប្រកាសលទ្ធផលអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ (CIAS2019) នាថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ២០២១ ខាងមុខនេះពីអង្គការ IFAD នឹងប្រកាសការប្រកួតប្រជែងផ្តល់ជំនួយសម្រាប់គម្រោងស្រាវជ្រាវដោយប្រើទិន្នន័យ CIAS2019។

IFAD នឹងផ្តល់ឱកាសជាថវិកាដល់អ្នកស្រាវជ្រាវក្នុងស្រុកនៅក្នុងប្រទេសកម្ពុជាដើម្បីទទួលបានជំនួយសម្រាប់គម្រោងស្រាវជ្រាវដោយប្រើទិន្នន័យ CIAS2019។ ការងាររបស់ IFAD នៅកម្ពុជាមានសារៈសំខាន់ណាស់និ ងមានភាពពាក់ព័ន្ធនិងទាន់ពេលវេលាសំរាប់ការអភិវឌ្ឍន៍កសិកម្មនិងជនបទនៅកម្ពុជា។

**ទំនាក់ទំនង**:
**១. លោកជំទាវ ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអគ្គនាយក វិទ្យាស្ថានជាតិស្ថិតិ
ទូរស័ព្ទដៃ: (៨៥៥) ១២ ៧២៣ ១០៧ អ៊ីម៉ែល: linahang2002@gmail.com
អគា ៣៨៦ មហាវិថីព្រះមុន្នីវង្ស, សង្កាត់បឹងកេងកង ១ ខ័ណ្ឌបឹងកេងកង រាជធានីភ្នំពេញ កម្ពុជា។
**២. ឯកឧត្តម សុក កុសល** អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ
ទូរស័ព្ទដៃ: (៨៥៥) ១២ ៩៧៣ ៥៩៨, អ៊ីម៉ែល: kosalsok379@gmail.com
អគា ៣៨៦ មហាវិថីព្រះមុន្នីវង្ស, សង្កាត់បឹងកេងកង ១ ខ័ណ្ឌបឹងកេងកង រាជធានីភ្នំពេញ កម្ពុជា។